សារៈ នៃ ប្រាជ្ញា

សារៈ នៃ ប្រាជ្ញា

មនុស្សមានប្រាជ្ញា មាន ប្រយោជន៏ដល់ ខ្លួនឯង និង ជាតិ លុះតែ មនុស្សនោះ ជាមនុស្ស មានមារយាទ គឺប្រព្រឹត្តត្រូវតាមកន្លងធម៏។ ព្រះរាជសម្ភារថា : « *អសារមានបី បណ្តាំមេជី ព្រេងព្រឹទ្ធប្រដៅ អង្ករសសុទ្ធ ចម្អិនអោយនៅ ពិសីហើយខ្លៅ ប្រាជ្ញឥតមារយាទ* » និង នៅក្នុងកាព្យមួយថា : « *អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ន្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនិងសំប៉ាន* » និង បុរាណភាសិតថា : « *ប្រាជ្ញាបុណ្យផង កើតដោយប្រតិបត្តិ* »។ ដូចនេះ សារៈ នៃ ប្រាជ្ញា វាអាស្រ័យនឹង អំពើល្អដែលអ្នកមានប្រាជ្ញាប្រព្រឹត្ត បានសម្រេចហើយ គឺថា បុគ្គលធ្វើបុណ្យ រមែងតែប្រាប្ត[1] កុសលកម្មណាមួយ។

អ្នកដែលតាំងខ្លួនឯង ជា អ្នកប្រាជ្ញ ឬ បណ្ឌា ឬ បណ្ឌិត[2] តែឥតមារយាទ បណ្តែគំនិតអាក្រក់ អោយយល់ថា ល្អ ព្រោះ ខ្លួនគង្គួននឹងកុសល គឺ ជា មនុស្សខូច ឬ មនុស្សមានពុតត្បុត។ មនុស្សបែបនោះ ច្រើនតែជា អ្នកបំរើ ពួកជនផ្តាច់ការ ឬ

---

[1] ប្រាប្ត : ដែលបានដល់ហើយ, បានសម្រេចហើយ។

[2] បណ្ឌិត សំរាប់ ហៅគ្រហស្ថកំលោះដែលទើបតែសឹកចាកផ្នួសថ្មី។ តែក្រោយមកហៅក្លាយមកថា បន្ទិត, ហៅក្លាយឃ្លាតមកថា អន្ទិត ព្រោះគេយល់ថា អ្នកនោះបានបួស មានការចេះដឹង មានចរិយាមារយាទត្រឹមត្រូវ។ ពាក្យសន្មតប្រើតាមសម័យនិយម, ហៅអ្នកមានវិជ្ជាថ្នាក់ខ្ពស់ ដែលមានសញ្ញាបត្រ Doctorat ថា បណ្ឌិត ដុកទ័រ។

សារៈ នៃ ប្រាជ្ញា

ក្រុមចោរ ទទួលបានកម្រៃ ជា យសស័ក្តិ និង ប្រាក់ ព្រោះ ចិត្ត គ្មានហិរិ[3]។ ជនពាលោនោះ និយាយពព្រាត[4] ជា ពាហិរកថា[5] ថា យួន បាត់ដី ព្រោះ ខ្មែរ បំពាន ដូច ករណី លោក ហេង សំរិន ធ្លាប់យកដីយួន មកសង់ផ្ទះ និង និយាយការពារ ប្រភូ[6]ខ្លួន ដូចយ៉ាង ធ្វើសង្គ្រាម, វៃបាក់ធ្មេញ, វៃក្បាលនឹងគល់ឬស្សី ចំពោះពួកអ្នកប្រឆាំងនឹង លទ្ធផលបោះឆ្នោត ថាជា ពាក្យ សាមញ្ញខ្មែរ។ គំនិតបកស្រាយ បែបនេះ ហាក់បីទុក សង្គមខ្មែរ ជា សង្គមអនារ្យធម៌ គ្មានមាន វចីសុច្ចរិត នៅក្នុងមជ្ឈដ្ឋាន នៃ ពួកអ្នកដឹកនាំជាតិ និង គ្មាន ខ្មែរអ្នកជា សំរាប់យល់ដឹងពី ការពិត។ ពួកអ្នកប្រាជ្ញទុច្ចរិត ទាំងនោះ មាន សម្មតិនាម ជា ‹អ្នកប្រូ› ឬ ‹មនុស្សក្រាប[7]› តើពួកគាត់ជាសត្វអ្វីហ្ន ? បើទុក ជា មនុស្ស តើជា ជនប្រភេទណា ? ចុះបើទុក ជា មនុស្សពាល តាំងខ្លួនជាអ្នកចេះ (aliboron) ប្រហែល ជា ន័យនេះ ប្រាប់លក្ខណៈពិត នៃ តិរច្ឆាន ហ្នឹងហើយ។ យើងឃើញថា សារៈ នៃ ប្រាជ្ញា វាអាចជា បរាភព (ruine) ដល់ប្រជាជាតិ បើ ប្រាជ្ញានោះ វាគ្មាន មនសិការជាតិ។ ដូច្នេះ រស់មួយពេល ដើម្បីជាតិ ដូច ករណី លោក កែម ឡី វាប្រសើរជាងបន្តរស់ ដើម្បីចោរ៕

---

3 គ្មានហិរិ, គ្មានសេចក្តីខ្មាស់នឹងអំពើអាក្រក់។

4 និយាយពព្រាត, ដែលបញ្ចេញវាចាតាមតែរួចពីមាត់ឥតបើគិតពីខុសពីត្រូវ។

5 ពាហិរកថា, សម្តីក្រៅពីពាក្យពិត។

6 ប្រភូ, ម្ចាស់ ចៅហ្វាយ។

7 មនុស្សក្រាប, មនុស្សខូច ជា អ្នកនាំពាក្យ។